បណ្ឌិត ជា ឈោង

# ជំនឿខ្មែរ

ឆ្នាំ ១៩៩៨

បណ្ឌិត ជា ណេង

នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល
ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# ជំងឺជ្រូក

ម.ព.ឯ.ក AIDOC
Code: 241-003
Date:
Donated by:

ឆ្នាំ ១៩៩៨

# ជំងឺបង្កឡើងដោយវីរុស

*Maladies à virus*
*Virus Diseases*

## ជំងឺផ្តាសាយ

**La grippe du porc**
**Flu, Hog Flug, Swine flu**
**Swine influenza**

ជំងឺផ្តាសាយ ច្រើនកើតនៅកន្លែងចិញ្ចឹមខ្វះអនាម័យ និង ខ្វះពន្លឺថ្ងៃ ។ ជាជំងឺផ្លូវដង្ហើម ហើយក្នុងកំរិតធ្ងន់ អាចឆ្លងរាលដាលយ៉ាងរហ័ស ។ ជំងឺនេះច្រើន កើតនៅរដូវភ្លៀង និង ពេលផ្លាស់ប្តូររដូវ ។

ជំងឺផ្តាសាយ កើតឡើងដោយការផ្សំគ្នានៃមេរោគ Hémophilus influenzae និង វីរុសនៃជំងឺផ្តាសាយរបស់ជ្រូក ។

គឺវីរុសនៃជំងឺផ្តាសាយជាអ្នកបង្កឱ្យមានជំងឺ ប៉ុន្តែបើមានតែម្នាក់វា នោះ មិនបណ្តាលឱ្យមានជំងឺធ្ងន់ធ្ងរទេ ។ ចំណែក Hémophilus influenzae តែម្នាក់វាក៏មិនបង្កឱ្យមានជំងឺដែរ ប៉ុន្តែនៅពេលដែលវាទាំងពីរបូកបញ្ចូលគ្នា នោះនឹងបណ្តាលឱ្យមានជំងឺផ្តាសាយធ្ងន់ធ្ងរ ឆ្លងរាលដាលរហ័ស

ហើយក្នុងលក្ខណៈខ្លះ គេឃើញវានៅលាយឡំជាមួយនឹងមេរោគ Pasteurella multocida ទៀតផង ។

## ប្រវត្តិសង្ខេប :

គេបានរកឃើញជំងឺផ្តាសាយជ្រូកតាំងពីឆ្នាំ១៩១៨ ។ បណ្ឌិត J.S.Koen( ១៩២២ ) និយាយថា ជំងឺផ្តាសាយជ្រូកមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងជំងឺផ្តាសាយរបស់មនុស្ស ។ គេមានការលំបាកក្នុងការបែងចែកជំងឺផ្តាសាយជ្រូក និង ជំងឺផ្តាសាយមនុស្ស ព្រោះជំងឺទាំងពីរនេះមានរោគសញ្ញាដូចគ្នា : ក្តៅ ក្អក មិនស្លូវ ស៊ីចំណី ពិបាកដកដង្ហើម ។

ជ្រូកដែលកើតជំងឺផ្តាសាយ ដេកគរលើគ្នាមួយកន្លែង ។ ជំងឺនេះឆ្លងរាលដាលរហ័សណាស់ ក្នុងមួយឆ្នាំ ១៩១៨ វាបានសម្លាប់ហ្វូងជ្រូកនៅលើពិភពលោកអស់ចំនួន ២១លានក្បាល ។ បច្ចុប្បន្នជំងឺផ្តាសាយជ្រូកកើតមានគ្រប់ទីសទីក្នុងពិភពលោក ។

## ការឆ្លងរាលដាល :

ជ្រូកដែលមានជំងឺផ្តាសាយ អាចចំលងទៅជ្រូកជាបានយ៉ាងឆាប់រហ័ស ។ កូនជ្រូកអាយុតិចជាងមួយខែ មានជំងឺនេះច្រើនជាងជ្រូកធំ ។ នៅប្រទេសយើង ជំងឺនេះច្រើនកើតនៅដើមរដូវភ្លៀង ។ លក្ខណៈពិសេសនៃជំងឺនេះ គឺកើតមានយ៉ាងរហ័ស ហើយឆ្លងរាលដាលយ៉ាងលឿន ក្នុងរយៈពេលតែពីរ-បីថ្ងៃ ជ្រូកទាំងអស់ក្នុងទ្រុងសុទ្ធតែមានជំងឺនេះ ។

រោគសញ្ញា ៖

រយៈពេលសម្ងំរបស់មេរោគគឺ ៣-៦ថ្ងៃ ។ ជំងឺកើតឡើងរហ័ស បណ្តាលឱ្យជ្រូកក្តៅ មិនស៊ីចំណី ក្អក ។ នៅថ្ងៃទីបី កំដៅខ្លួនឡើងដល់ ៤១,៤°-C រួចចុះមកវិញ ជ្រូកក្អកយ៉ាងខ្លាំង ពិបាកដកដង្ហើម ហៀរសំបោរ ខាប់ ពពឹកភ្នែក ហើមសួត ។ ជ្រូកឈឺ ច្រើនងាប់នៅថ្ងៃទី ៣, ៤, ៥ ឬទី ៦ អាស្រ័យទៅតាមសភាពរបស់ជំងឺធ្ងន់ ឬ ស្រាល ។ ជ្រូកដែលមិនងាប់ពីជំងឺនេះចិញ្ចឹមក្រធំ ។

ប្រសិនបើយើងថែទាំវាបានល្អ តែក្នុងរយៈពេល ៣-៧ថ្ងៃ ជ្រូកអាចជា ប៉ុន្តែនៅតែក្អក រហូតដល់បីអាទិត្យទើបបាត់ ។

វិធីការពារ ៖

គ្មានថ្នាំការពារជំងឺផ្តាសាយជ្រូកទេ ។ មធ្យោបាយការពារជំងឺផ្តាសាយដ៏ប្រសើរបំផុត គឺត្រូវចិញ្ចឹមជ្រូកក្នុងទ្រុងស្ងួត មិនសើមប៉ផ្ចិចប៉ផ្ចាច់ កក់ក្តៅ និង មានខ្យល់អាកាសចេញ-ចូល ។

ការព្យាបាល ៖

- លាយ Sulfathiazole ក្នុងទឹកឱ្យជ្រូកឈឺផឹកក្នុងរយៈពេលពីរថ្ងៃ រួចហើយឱ្យជ្រូកផឹកទឹកថ្លាស្អាតពីរថ្ងៃទៀត បើមិនឃើញមានលទ្ធផលទេ លាយ Sul-fathiazole ឱ្យផឹកមួយថ្ងៃទៀត ។

- ចាក់វីតាមីន C ជួយឱ្យជ្រូកឆាប់ជាពីជំងឺ

- ក្នុងករណីជ្រូករលាកសួត ត្រូវចាក់ Streptomycine ឬ Pénicilline ឬក៏ប្រើ Auréomycine ចាក់ក៏បាន ផឹកក៏បាន ។

### តើជំងឺផ្តាសាយជ្រូកឆ្លងមកមនុស្សដែរឬទេ ?

ពិតជាការគួរឱ្យចាប់អារម្មណ៍ ព្រោះថាជំងឺផ្តាសាយជ្រូកកើតមាននៅឆ្នាំ ១៩១៨ បណ្តាលមកពីជំងឺផ្តាសាយរបស់មនុស្ស ក៏ប៉ុន្តែជំងឺនេះស្ថិតនៅស្ថេរភាព តែលើសត្វជ្រូកមិនបង្កឱ្យមានជំងឺដល់ជីវិតសត្វលោកដទៃទៀតទេ ។

## ជំងឺប៉េស្តជ្រូក

**La peste porcine**

**Hog Cholera - Swine fever**

ដោយសារវិធានការពារមានលក្ខណៈល្អប្រសើរ ជំងឺប៉េស្តជ្រូកត្រូវកំចាត់ចេញជាស្ថាពរពីប្រទេសអាមេរិក និង ពីប្រទេសមួយចំនួនទៀតដូចជា អង់គ្លេស កាណាដា ដាណឺម៉ាក អូស្ត្រាលី ។ ល ។

ការចំលងជំងឺជាទូទៅគឺតាមរយៈផ្លូវរំលាយអាហារ និង តាមផ្លូវដង្ហើម។

ជំងឺប៉េស្តជ្រូក ជាជំងឺឆ្លងកាចសាហាវ បង្កឡើងដោយសារវីរុសមួយប្រភេទ ។ ជំងឺនេះកើតមានជាលើកដំបូងនៅឆ្នាំ ១៨៣៣ នៅរដ្ឋ Ohio សហរដ្ឋអាមេរិករួចហើយឆ្លងរាលដាលពាសពេញសហរដ្ឋទាំងមូល។

ជំងឺប៉េស្តជ្រូកកើតមានតែនៅលើសត្វជ្រូក ទន្សាយ ចៀម ពពែ សត្វ ដទៃទៀតមិនកើតជំងឺនេះទេ តែអាចពាំមេរោគចំលងឱ្យសត្វជ្រូក ។

រោគសញ្ញា :

មិនស៊ីចំណី ទុក្ខព្រួយ រសេះរសោះ ហេវហត់ ទន់ខ្សោយ ខ្ជិល ដើរ ជាញឹកញាប់ឈរបង្អួរជើង ហាក់បីដូចជាដើម្បីសំរាលការឈឺចាប់ ឈរមិនជាប់ ជួនប្រឹងងើបឈរ តែត្រូវដួលទៅវិញ ច្រើនដេកមួយកន្លែង ជ្រូកមួយចំនួនញ័រញាក់ ងងឹតភ្នែក កំដៅឡើងដល់ ៤១-៤២°C ហៀរទឹកភ្នែកព្រមទាំងមានពពឹកស្អិតជាប់ គ្របកភ្នែកទាំងលើទាំងក្រោម ជួនកាលមានហៀរសំបោរ ដំបូងរាវ ក្រោយមកក្លាយជាក្រមរស្ងួតនៅចុងច្រមុះ រាំងស្ទះការដកដង្ហើម ។ ទោះបីជាពពឹកភ្នែកបិទជិតភ្នែក ជាសញ្ញាសំគាល់នៃជំងឺប៉េស្តជ្រូកក៏ដោយ ក៏មានករណីខ្លះគ្មានរោគសញ្ញានេះដែរ ។ ក្រោយមកទល់លាមក ក្អៀនមួយរយៈខ្លី រួចហើយរាគរូសយ៉ាងខ្លាំង លាមកពណ៌លឿង ក្លួតចង្អោរ ក្នុងលាមក និង ក្នុងកំអួត អាចនឹងឃើញមានព្រូនចង្កឹះ ( Ascaris ) ប្រសិនបើជ្រូកនោះមានព្រូនចង្កឹះ ។ បន្ទាប់មកទៀតជ្រូកអាចនឹងទល់លាមកឡើងវិញ បើគ្មានជំងឺស្មុគ្រស្មាញរួមផ្សំទេ ។ បន្ទាប់មកមានកកឈាមដុំតូចៗនៅក្រោមស្បែក កន្ទួលក្រហមនេះអាចមើលឃើញច្បាស់នៅលើជ្រូកដែលមានសម្បុរស នៅកន្លែងស្បែកស្តើង ដូចជានៅលើត្រចៀក រន្ធត្រចៀក ច្រមុះ ភ្លៅ និង ពោះ ។ល។ កន្ទួលក្រហមតែមួយមុខ មិនអាចឱ្យយើងកំណត់បានថាជាជំងឺប៉េស្តទេ ព្រោះជំងឺផ្សេងទៀតក៏មានរោគសញ្ញាបែបនេះដែរ ។ កន្ទួលក្រហមនៅលើជ្រូកកើតជំងឺប៉េស្ត មានពណ៌ក្រមៅ ហើយរាលធំជាងកន្ទួលក្រហមនៅលើជំងឺកញ្ជ្រិល ។ ក្នុងសភាពជំងឺរ៉ាំរ៉ៃ ជួនពេលខ្លះមិនមានកន្ទួលក្រហមនេះទេ ។